64/5

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

— ✵ —

សាលាឧទ្ធរណ៍ភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១៥២/ ១១-០៣-២០១០
សាលដីកា
លេខ ០២ ក្រVI ·ញ· / ២៧-០១-២០១២

# តាងនាមប្រជារាស្ត្រខ្មែរ

# សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍

ឆ្នាំពីរពាន់ដប់ពីរ ខែមករា ថ្ងៃទីម្ភៃប្រាំពីរ វេលាម៉ោងប្រាំបីព្រឹក បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ ដែលមានសមាសភាពដូចខាងក្រោម:

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

១-លោក [redacted] ជាប្រធាន

២-លោក [redacted] ជាចៅក្រមប្រឹក្សា

៣-លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted]

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍នៃសំណុំរឿងព្រហ្មទណ្ឌលេខ ១៥២ ចុះថ្ងៃទី ១១-០៣-២០១០ រវាង:

**ជនជាប់ចោទឈ្មោះ** [redacted] ភេទប្រុស អាយុ ២៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិក្រាំង ឃុំក្រាំងអំពិល ស្រុកកំពង់បាយ ខេត្តកំពត មានទីលំនៅភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត សាសនា ព្រះពុទ្ធ របររកស៊ី គ្រូបង្រៀន ឪពុកឈ្មោះ [redacted] ·ស· ម្ដាយឈ្មោះ [redacted] ពន្ធឈ្មោះ: [redacted] នកូន ១នាក់ ទោសពីមុនគ្មាន ឃុំខ្លួននៅថ្ងៃទី ២០-០៣-២០០៩ ។

មេធាវីការពារ លោក [redacted]

**<u>ត្រូវចោទពីបទ:</u>** ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី ១៩-០៣-២០០៩ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

**និងដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ** [redacted] ភេទប្រុស អាយុ ៤០ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃ ភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត ។



Scanned by CamScanner

**ងរឿងហេតុដូចខាងក្រោម:**

តាមកំណត់ហេតុបណ្តឹងចុះថ្ងៃទី ២០-០៣-២០០៩ របស់ឈ្មោះ[redacted]ង បញ្ជាក់ថា នៅថ្ងៃទី ២០-០៣-២០០៩ វេលាម៉ោង ៦ និង ២០នាទី មានប្អូនជីដូនមួយរបស់ប្រពន្ធខ្លួនឈ្មោះ[redacted] បានឃើញប្អូនប្រុសរបស់ខ្លួនឈ្មោះ[redacted] ស្លាប់ដេកពោបលើខ្សែលួសបន្លា ហើយនាំប្អូនជីដូនមួយខ្លួនម្នាក់ទៀតឈ្មោះ[redacted] មកប្រាប់ខ្លួន[redacted]ាប់ហើយ ដោយសារឆក់ខ្សែភ្លើង ។ ភ្លាមនោះខ្លួនក៏បានហៅឪពុកក្មេកខ្លួនឈ្មោះ[redacted]និងឈ្មោះ [redacted] ទៅដល់កន្លែងកើតហេតុ ឃើញប្អូនរបស់ខ្លួនឈ្មោះ[redacted]ានដេកស្លាប់ដោយយកដៃទាំងពីរកេល់លើខ្សែលួស ក្បាលងើបឡើងលើ ឃ្លាតចម្ងាយ ៨០ ម៉ែត្រ ពីត្បូងផ្ទះខ្លួន បែរមុខសំដៅផ្ទះរបស់ឈ្មោះ[redacted]លស្ថិតនៅក្រោយរបងផ្ទះឈ្មោះ [redacted] ហើយខ្លួនបានសែងសពមកផ្ទះឃើញមានរលាកកំភួនដៃចំនួន ៦កន្លែង រលាកក្រោមដើមដៃឆ្វេង ១កន្លែង និងស្មាម រលាកដើមទ្រូង ៣កន្លែង ។ សំណូមពរ សុំទាមទារជម្ងឺចិត្តចំនួន ៥.០០០ ដុល្លារអាមេរិក ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៥២ ចុះថ្ងៃទី ២៨-០២-២០១០ របស់សាលាដំបូងខេត្តកំពត សម្រេចមានខ្លឹមសារដូចខាងក្រោម:

ឲ្យឈ្មោះ[redacted]ភេទប្រុស អាយុ ២៨ ឆ្នាំ រួចខ្លួនពីបទ: ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី ១៩-០៣-២០០៩ បទល្មើសដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី ០៧-០១-២០០២ និងយោងតាមមាត្រា ៣៥០ នៃក្រមនីតិវិធី ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនាថ្ងៃទី ២៨-០២-២០១០ ចំពោះមុខគូភាគី បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

- បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៦-០២-២០១០ របស់ឈ្មោះ ជុំ សាបាន ។
- បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៥-០២-២០១០ របស់ឈ្មោះ[redacted]
- បានឃើញសេចក្តីសន្និដ្ឋានចុះថ្ងៃទី.............................របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។

**នាពេលសវនាការ**

- ជនជាប់ចោទឈ្មោះ[redacted] (មិនចូល)
- មេធាវីការពារ លោក[redacted] (ចូល)
- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted] (ចូល)



Scanned by CamScanner

## ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុ

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] បានឆ្លើយថា: ពីមុនប្អូនខ្លួនធ្លាប់ចេញ-ចូល ខ្លួនទៅកន្លែងកើតហេតុឃើញខ្សែភ្លើងចេញពីរបង ពេលខ្លួនឲ្យប្អូនទៅប្តឹងសមត្ថកិច្ច វាក៏ប្រមូលអស់ ។ របងចូលដីឡូត៍គេ លុះម៉ោង ៦ ភ្លឺ ទើបដឹងថាប្អូនស្លាប់ ប្អូនខ្លួនដើរប៉ះខ្សែភ្លើងនៅពេលយប់ ខ្សែភ្លើងឆក់លើរបងខ្សែលួស ។ ពេលឃើញប្អូនស្លាប់ជាប់ខ្សែលួស ខ្សែភ្លើងចងជាប់ខ្សែលួស ២ជ្រុង (L) របងមានមុនកើតហេតុប្រហែលមួយខែ ហើយផ្លូវនោះគេបិទ ។

- ខ្សែភ្លើង ខ្លួនមិនចាប់អារម្មណ៍ពណ៌អ្វីទេ ខ្លួនឃើញប្អូននៅម៉ោង ៦ភ្លឺ សមត្ថកិច្ចមកដល់ម៉ោង ៧ និងឃើញមានអង់តែនទូរទស្សន៍ ពេលនោះមានភ្លៀងធ្លាក់ខ្លាំង ។ ពីមុនមកពុំដែលមានទំនាស់អ្វីនឹងគ្នាទេ ។

- ខ្លួនសំណូមពរសុំឲ្យផ្តន្ទាទោសតាមច្បាប់ ។

## តំណាងមហាអយ្យការសន្និដ្ឋាន

យោងតាមការដេញដោល ពុំមានភស្តុតាងណាបញ្ជាក់ថា ជនល្មើសដាក់ខ្សែភ្លើងធ្វើឲ្យមនុស្សស្លាប់នោះទេ សុំក្រុមប្រឹក្សាសម្រេចតាមច្បាប់ ។

## មេធាវីធ្វើសេចក្តីសន្និដ្ឋាន

- ដើមបណ្តឹងថា ឃើញខ្សែភ្លើងបណ្តាលឲ្យប្អូនខ្លួនស្លាប់ តែគាត់មិនដឹងថាពណ៌អ្វីទេ ។

- តាមការបញ្ជាក់ពីសមត្ថកិច្ច គឺគ្មានឃើញខ្សែភ្លើងចេញពីផ្ទះជនល្មើសទេ បញ្ជាក់ថាមានអង់តែនទូរទស្សន៍ ដូចនេះការស្លាប់នេះ វាអាចគេសម្លាប់ហើយយកមកទម្លាក់ចោលនៅទីនោះ ហេតុនេះការចោទប្រកាន់កូនក្តីខ្លួន គឺមិនត្រឹមត្រូវទេ សុំតម្កល់។

## ក្រុមប្រឹក្សាជំនុំជម្រះថយពិភាក្សា និងប្រកាសសាលដីកា

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៦-០២-២០១០ របស់លោក [redacted] (អយ្យការ) ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន យោងតាមមាត្រា ៣៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៥-០២-២០១០ របស់ [redacted] ដើមបណ្តឹងរដ្ឋប្បវេណី) ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន យោងតាមមាត្រា ៣៨២ និង ៤០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។



Scanned by CamScanner

៣-តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅពេលសវនាការសាលាឧទ្ធរណ៍ បានបញ្ជាក់ថា: នៅថ្ងៃទី ២០-០៣-២០០៩ វេលាម៉ោង ៦ និង ២០នាទី នៅពេលដែលបានទទួលដំណឹងថា ប្អូនរបស់ខ្លួនឈ្មោះ[redacted]ស្លាប់ ខ្លួនក៏បានទៅដល់កន្លែងកើតហេតុ ឃើញប្អូនខ្លួនដេកស្លាប់ ដោយយកដៃទាំងពីរកល់លើខ្សែលួស ក្បាលងើបឡើង បែរមុខសំដៅទៅផ្ទះឈ្មោះ[redacted]ពលខ្លួនសែងសពចេញ ឃើញលោកកំភួនដៃ ៦កន្លែង លោកក្រោមដៃឆ្វេង ១កន្លែង និងស្នាមលោតដើមទ្រូង ៣កន្លែង ។ នៅពេលខ្លួនទៅដល់កន្លែងកើតហេតុភ្លាម ខ្លួនឃើញខ្សែភ្លើងតចេញពីផ្ទះឈ្មោះ[redacted]ដោយចុងខ្សែភ្លើងមានចងជាអង់តែនភ្ជាប់មកលួសបន្លាបងដែលជនរងគ្រោះដេកស្លាប់ ។ ម្យ៉ាងទៀតតាមចម្លើយសាក្សីថា បានឃើញជនជាប់ចោទស្រាវខ្សែភ្លើងចេញពីកន្លែងកើតហេតុ និងបានឮជនជាប់ចោទហាមមិនឲ្យទៅក្បែរកន្លែងកើតហេតុ ប្រយ័ត្នឆក់ខ្សែភ្លើងស្លាប់។

៤-តាមប្លង់រូបកន្លែងកើតហេតុចុះថ្ងៃទី ២០-០៣-២០០៩ របស់ស្នងការនគរបាលខេត្តកំពត បានបញ្ជាក់ថា ជនរងគ្រោះពិតជាបានស្លាប់ដោយសារភ្លើងឆក់ប្រាកដមែន។

៥-មានពិរុទ្ធភាពគ្រាប់គ្រាន់លើឈ្មោះ[redacted]ភេទប្រុស អាយុ ២៨ ឆ្នាំ ពីបទៈ មនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី ១៩-០៣-២០០៩ តាមមាត្រា ៨ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៦-ជនជាប់ចោទទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង និងការប្រព្រឹត្តនេះក្នុងគោលបំណងការពារទ្រព្យសម្បត្តិរបស់ខ្លួន និងគ្មានគោលដៅសម្លាប់ជនរងគ្រោះឡើយ ដូចនេះ គប្បីក្រុមប្រឹក្សាពិចារណាកម្រិតនៃការផ្តន្ទាទោសអប្បបរមាឲ្យជនជាប់ចោទ ។

៧-ដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងទាមទារសំណងជម្ងឺចិត្តចំនួន ៥.០០០ដុល្លារអាមេរិក គប្បីក្រុមប្រឹក្សាពិចារណា ។

៨-សាលក្រមព្រហ្មទណ្ឌលេខ ៥២ ចុះថ្ងៃទី ២៤-០២-២០១០ របស់សាលាដំបូងខេត្តកំពត សម្រេចពុំត្រឹមត្រូវតាមច្បាប់ឡើយ គប្បីបដិសេធចោលជាអសារបង់ និងសម្រេចផ្តន្ទាទោសជនជាប់ចោទតាមការយល់ឃើញខាងលើ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ២៦-០២-២០១០ របស់លោក[redacted] និងចុះថ្ងៃទី ២៥-០២-២០១០ របស់[redacted]ជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។



Scanned by CamScanner

៦៤

២-បដិសេធសាលក្រមព្រហ្មទណ្ឌលេខ ៥២ ចុះថ្ងៃទី ២៨-០២-២០១០ របស់សាលាដំបូងខេត្តកំពត ចោលជាអសារបង់ ។

៣-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៨ ឆ្នាំ ដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ ពីបទៈ មនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅភូមិក្រាំង សង្កាត់ក្រាំងអំពិល ក្រុងកំពត ខេត្តកំពត កាលពីថ្ងៃទី ១៩-០៣-២០០៩ តាមមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៤-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] សងសំណងជម្ងឺចិត្តចំនួន ១០.០០០.០០០ រៀល ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ណូមពរលើសពីនេះ បដិសេធចោល ។

៥-សម្រេចបន្តការឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] តាមនីតិវិធីច្បាប់ ។

៦-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី ២៧-០១-២០១២ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងតំណាងមុខជនជាប់ចោទ ទុកសិទ្ធិឲ្យប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែ០២ ឆ្នាំ ២០១២

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សា

[redacted]



Scanned by CamScanner